# កុមារគំរូ

## Being Good



សូមស្កេនQR Code

គំនូរជីវចល

ធនធានបង្រៀន

Written by TukTuk

Illustrated by Choven Hen






មកានិងរតនាពេលទៅសាលា
រៀនលេខរៀនអក្សរផង

តែងតែជិះកង់
ពេលសរសេរត្រូវតម្រង់ហើយរចនា។




ឯគ្រូសុខវិញ គឺជាគោព្រៃ ជាគ្រូមត្តេយ្យ
នៅឯសាលា គាត់គឺជាគ្រូ ដែលឧស្សាហ៍
គ្រប់មុខវិជ្ជាគាត់ចេះទាំងអស់។



កាលខ្ញុំនៅតូច ជាសិស្សកំហូច រៀនខ្លាចសាលា
ចូលរៀនដំបូង យំនឹកម៉ាក់ប៉ា មិនដឹងម៉ោងណា
គ្រូឱ្យទៅផ្ទះ។




អូ!!! ប្អូនដល់ម៉ោងចូលរៀនហើយ បងរតនា!

ចាស!!! ប្អូនទៅចុះ លាហើយ!

បាទ!!! ជម្រាបលា បងរតនា!




នៅក្នុងសាលា ត្រូវខំសិក្សា ក្រេបយកចំណេះ
វិជ្ជាជាស្ពាន ជាយានជំនិះ ជួយឱ្យយើងឈ្នះ
ផុតទុក្ខវេទនា។



ពេលឆ្ងល់ខ្ញុំសួរ អ្វីគួរមិនគួរ គ្រូតែងតែឆ្លើយ
ទូន្មានប្រដៅ ហើយជួយបកស្រាយ ជាហេតុធ្វើឱ្យ
ខ្ញុំចង់សិក្សា។



ជាកូនចៅល្អ
ត្រូវចេះស្តាប់គ្រូ

ត្រូវស្តាប់ពុកម៉ែ
ចេះគិតចេះគួរ
គោរពវិន័យ។

ជាសិស្សពូកែ
ជាសិស្សគំរូ



ពេលលេងខ្ញុំចេះគិត
ហើយត្រូវតែចេះ

ចែករំលែកមិត្ត
ជួយយកអាសា
ទាំងអស់គ្នា ។

បានលេងគ្រប់គ្នា
សប្បាយសុខា



ត្រូវចេះគោរពសិទ្ធ
ស្រលាញ់រាប់អាន

យើងគួរចេះគិត
មិត្តទាំងប្រុសស្រី
គ្នាទើបបានល្អ។

កុំរើសអើងអី
ចេះឱ្យតម្លៃ



ពលដល់ម៉ោងទៅផ្ទះ យើងត្រូវសំពះ ដម្រាបលាគ្រូ
នេះហើយគឺជា កុមារគំរូ ចេះគោរពគ្រូ
គោរពចាស់ទុំ។



នៅពេលទៅដល់ផ្ទះ គោរពសំពះ តាមក្បួនតម្រា

កូនមកវិញហើយ មកពីសាលា គោរពម៉ាក់ប៉ា

តាមប្រពៃណី។



ចូរកូនចៅខ្មែរទាំងប្រុសស្រី
ត្រូវថែវប្បធម៌ជាតិខេមរា

កុំភ្លេចប្រពៃណីពីដូនតា
ខ្មែរយើងថ្លៃថ្លាគង់វង្សអើយ។